**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..០២...សរ.ណន

# សារាចរណែនាំ

# ស្តីពី

# ការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក

កន្លងមកក្រសួង ស្ថាប័នបានធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅតាមមុខតំណែង និងកាំប្រាក់ចាស់ ដោយផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីតាមខ្លឹមសារនៃអនុក្រឹត្យ លេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ។ ទន្ទឹមនឹងនេះ ក្រសួងស្ថាប័នមួយចំនួនក៏បានធ្វើការតែងតាំងមន្ត្រីអោយចូលក្នុងក្របខ័ណ្ឌថ្មីដែរ ប៉ុន្តែពុំទាន់បានចប់សព្វគ្រប់តាមចំនួនក្របខ័ណ្ឌដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែកនីមួយៗ និងស្របតាមទិសដៅកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល។ ចំពោះមុខ ដើម្បីជំរុញការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែកនីមួយៗអោយបានឆាប់រហ័ស រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចខាងក្រោម :

១- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៅក្រោមឱវាទដោយកំណត់ឱ្យបានច្បាស់លាស់នូវមន្ត្រីដែលត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលទូទៅ ក្របខ័ណ្ឌក្រសួងមហាផ្ទៃផ្នែករដ្ឋបាល-ស៊ីវិល ក្របខ័ណ្ឌមន្ត្រីការទូត ក្របខ័ណ្ឌគ្រូបង្រៀន ក្របខ័ណ្ឌមន្ត្រីសុខាភិបាល ក្របខ័ណ្ឌបច្ចេកទេស ទៅតាមប្រភេទ ក ខ គ និង ឃ ដែលបានបង្កើតតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក។

២- ចំពោះប្រភេទក្របខ័ណ្ឌនីមួយៗ ក្រសួង ស្ថាប័នត្រូវកំណត់អោយបានច្បាស់លាស់នូវមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តិ ទី១ ឋានន្តរស័ក្តិទី២ និងឋានន្តរស័ក្តិ ទី៣ ទៅតាមសមាមាត្រកំរិតអតិបរមា ៥ភាគរយ ក្នុងឋានន្តរសក្តិទី១ និង ២៥ភាគរយ ក្នុងឋានន្តរស័ក្តិទី២ ដោយធ្វើការប្រៀបធៀបទៅនឹងចំនួនមន្ត្រីសរុបនៅក្នុងប្រភេទក្របខណ្ឌ័នីមួយៗ។

៣- ដើម្បីបំពេញសមាមាត្រក្នុងឋានន្តរស័ក្តិទី១ និង ទី២ ក្រសួង ស្ថាប័ន ត្រូវធ្វើការវាយតម្លៃអោយបានម៉ត់ចត់បំផុត ដោយផ្អែកលើលក្ខណៈសម្បត្តិ និងមុខតំណែងដែលទទួលខុសត្រូវរបស់មន្ត្រីរាជការនៃ

ក្របខ័ណ្ឌនីមួយៗ ដោយប្រើប្រាស់ឯកសារដែលក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានបោះពុម្ពធ្វើជាមូលដ្ឋានក្នុងការពិនិត្យ និងវាយតម្លៃ និងតាមនីតិវិធីផ្ទៃក្នុងនីមួយៗ។

៤- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ហើយបញ្ជូនទៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលដើម្បីធ្វើសុពលភាព ដោយមានការចូលរួមពីតំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីក្រសួង ស្ថាប័ន។

៥- ការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស អោយបានចប់ជាស្ថាពរនៅមុនដំណាច់ខែ មេសា ឆ្នាំ ២០០៤។ ដោយឡែកចំពោះក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើឱ្យបានចប់នៅត្រីមាសទី៣ នៃឆ្នាំ ២០០៤ ។

ទទួលបានសារាចរណែនាំនេះក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការ និងចាត់តាំងអនុវត្តអោយឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១. ខែ មិនា ឆ្នាំ ២០០៤

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ